# ភាពខុសគ្នារវាងការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស

**ការជួញដូរមនុស្ស**ពាក់ព័ន្ធនឹងការប្រើកំលាំងបាយ ការបោកប្រាស់ ឬការបង្ខិតបង្ខំ ដើម្បីទទួលបានកម្លាំងពលកម្មប្រភេទណាមួយ ឬការរួមភេទជាអាជីវកម្ម ឬក្នុងនោះបុគ្គលដែលធ្វើការរួមភេទជាអាជីវកម្មមានអាយុក្រោម 18 ឆ្នាំ។

**ការរត់ពន្ធមនុស្ស**គឺជាការគេចវេសដោយចេតនាពីច្បាប់អន្តោប្រវេសន៍ ដោយការនាំយកជនបរទេសដែលគ្មានឯកសារគ្រប់គ្រាន់ចូលមកក្នុងសហរដ្ឋអាមេរិក ហើយនិងការដឹកជញ្ជូនខុសច្បាប់ ព្រមទាំងលាក់ទុកដោយខុសច្បាប់នូវជនបរទេសគ្មានឯកសារត្រឹមត្រូវដែលបានស្ថិតនៅក្នុងសហរដ្ឋអាមេរិករួចហើយ។

## ទាំងនេះមិនមែនជាពាក្យដែលអាចប្រើជំនួសគ្នាបានទេ។

**ការរត់ពន្ធ**គឺសម្តៅលើការដឹកជញ្ជូន និងជាបទឧក្រិដ្ឋឆ្លងកាត់ព្រំដែនណាមួយ

**ការជួញដូរ**គឺសម្តៅលើការកេងប្រវ័ញ្ច និងជាឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលណាម្នាក់

BLUE CAMPAIGN
One Voice. One Mission. End Human Trafficking.®

សូមរាយការណ៍ពីការជួញដូរមនុស្ស៖ 1-888-373-7888
**www.dhs.gov/bluecampaign**

# ពេលកំណត់អត្តសញ្ញាណការជួញដូរមនុស្ស សូមសួរខ្លួនឯងថា៖

- ☐ តើជនរងគ្រោះមានឯកសារកំណត់អត្តសញ្ញាណ និងឯកសារធ្វើដំណើរផ្ទាល់ខ្លួនដែរឬទេ?
- ☐ តើជនរងគ្រោះត្រូវបានបង្ហាត់បង្រៀននូវអ្វីដែលត្រូវនិយាយទៅកាន់សមាជិកសហគមន៍ កម្មករ មន្ត្រីអនុវត្តច្បាប់ ឬមន្ត្រីអន្តោប្រវេសន៍ដែរឬទេ? តើមានអ្នកផ្សេងទៀតធ្វើការទំនាក់ទំនងជំនួសឲ្យជនរងគ្រោះដែរឬទេ?
- ☐ តើជនរងគ្រោះត្រូវបានជ្រើសរើសឲ្យចូលធ្វើការក្នុងគោលបំណងតែមួយប៉ុណ្ណោះ ប៉ុន្តែត្រូវបានបង្ខំឱ្យធ្វើការងារផ្សេងទៀតដែរឬទេ?
- ☐ តើប្រាក់ឈ្នួលរបស់ជនរងគ្រោះត្រូវបានរឹបអូសដោយខុសច្បាប់ដើម្បីសងបំណុល ឬថ្លៃសេវាកម្មណាមួយដែរឬទេ? (ការសងថ្លៃរត់ពន្ធតែម្យ៉ាងមិនត្រូវបានចាត់ទុកថាជាការជួញដូរនោះទេ។)
- ☐ តើជនរងគ្រោះត្រូវបានបង្ខំឱ្យធ្វើការរកស៊ីផ្លូវភេទដែរឬទេ?
- ☐ តើជនរងគ្រោះ ឬគ្រួសាររបស់ពួកគេមានត្រូវបានទទួលការគំរាមកំហែងដោយការធ្វើបាបដែរឬទេ ប្រសិនបើពួកគេព្យាយាមចាកចេញនោះ?
- ☐ តើជនរងគ្រោះមានត្រូវបានទទួលការគំរាមកំហែងដោយការនិរទេស ឬការចោទប្រកាន់ពីបទឧក្រិដ្ឋដែរឬទេ?
- ☐ តើជនរងគ្រោះមានបានទទួលការធ្វើបាប ការបង្អត់អាហារ ទឹក ការគេង ការថែទាំពីពេទ្យ ឬតម្រូវការចាំបាច់សម្រាប់ជីវិតផ្សេងទៀតដែរឬទេ?
- ☐ តើជនរងគ្រោះមានសេរីភាពក្នុងការទាក់ទងមិត្តភក្តិ ឬក្រុមគ្រួសារដោយមិនចាំបាច់ត្រូវមានការបង្ហាត់បង្រៀនឲ្យធ្វើដូច្នេះ ឬត្រួតពិនិត្យតាមដានដែរឬទេ?
- ☐ តើជនរងគ្រោះមានអាយុក្រោម 18 ឆ្នាំ និងប្រកបការរកស៊ីផ្លូវភេទដែរឬទេ?
- ☐ តើជនរងគ្រោះកំពុងរស់នៅក្នុងផ្ទះដែលមិនស័ក្តិសមក្នុងការរស់នៅតាមច្បាប់កំណត់ដែរឬទេ?